**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
**"រ.ទ.ស.ភ"**
លេខ ២៤៨ ល.ស

ភ្នំពេញ, ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៧

**<u>សូមជម្រាបជូន</u>**

**-លោកប្រធានក្រុមហ៊ុន អិកវ៉ាធើរ ថេកណូឡូជី**
**-លោកប្រធានក្រុមហ៊ុន នាគា ជ័យឧត្តម ខនស្ត្រាក់សិន**
**-លោកប្រធានក្រុមហ៊ុន សេង ហ្គេចហួង អេនធើប្រាយ**
**-លោកប្រធានក្រុមហ៊ុន ហង្ស សម្បត្តិ ខូអិលធីឌី**
**-លោកប្រធានក្រុមហ៊ុន ហ្វ្រេនស៊ីប សឹបផ្លាយ**

**<u>កម្មវត្ថុ</u>**: ប្រកាសលុបចោលការដេញថ្លៃផ្គត់ផ្គង់ឧបករណ៍បុកដែក ដែកបុកទប់ដី និងដែកសន្លឹក។

**<u>យោង</u>**: កំណត់ហេតុបើកឯកសារដេញថ្លៃ ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនលោកប្រធានក្រុមហ៊ុនមេត្តាជ្រាបថា៖ យោងតាមការវាយតម្លៃលើឯកសារដេញថ្លៃរបស់ក្រុមហ៊ុនស្ដីពីការផ្គត់ផ្គង់ឧបករណ៍បុកដែក ដែកបុកទប់ដី និងដែកសន្លឹក ឃើញថាតម្លៃដែលដាក់ដោយក្រុមហ៊ុនខ្ពស់ជាងឥណទានជានាចំណាយច្រើនពេក។ ដូចនេះរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញសូមប្រកាសលុបចោលការដេញថ្លៃនេះ និងប្រកាសដេញថ្លៃសារជាថ្មីក្នុងពេលឆាប់ដែលអាចធ្វើបាន។

ក្រុមហ៊ុនអាចដាក់ពាក្យដកប្រាក់កក់ធានាការដេញថ្លៃពីរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ នៅរាល់ម៉ោងធ្វើការចាប់ពីថ្ងៃប្រកាសនេះតទៅ។ ការដេញថ្លៃសារជាថ្មីនឹងត្រូវប្រកាសជូននៅពេលក្រោយ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកប្រធានមេត្តាជ្រាប និងអនុវត្តស្រ័យតាមការគួរ។

សូមលោកប្រធានទទួលនូវការគោរពរាប់អានពីខ្ញុំ។

**ជ. គណៈកម្មាធិការលទ្ធកម្ម**
**អនុប្រធានទី១**

**បណ្ឌិត ជា វិសុទ្ធ**

<u>ចម្លងជូន៖</u>
-គ្រប់សមាជិកគណៈកម្មាធិការលទ្ធកម្ម
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ
"ដើម្បីជ្រាបជាព័ត៌មាន"
-ឯកសារ-កាលប្បវត្តិ

អាសយដ្ឋាន: លេខ៤៥ ផ្លូវ ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ទូរស័ព្ទ: ៨៥៥(២៣) ៧២៤ ០៤៦ Email: admin@ppwsa.com.kh